ឧបសម្ព័ន្ធ ក.១

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រកាសអំពី
## ក្រមសីលធម៌ ការមិនក្លែងបន្លំ និងមិនប្រព្រឹត្តិអំពើពុករលួយ

ក្នុងឋានៈជាអ្នកផ្តល់សេវាបច្ចេកទេស ខ្ញុំសូមប្រកាសថាៈ

១. ខ្ញុំ និយោជិតរបស់ខ្ញុំ អ្នកផ្តល់សេវាបច្ចេកទេសរបស់ខ្ញុំ សមាគម/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ភាគហ៊ុនិករបស់ខ្ញុំ សម្ព័ន្ធញាតិរបស់ខ្ញុំ និងសមាគត និងសម្ព័ន្ធញាតិរបស់ពួកគេ គ្មានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជា ទំនាស់ផលប្រយោជន៍ ដូចមានចែងនៅក្នុងឯកសារកិច្ចសន្យាឡើយ។

២. ប្រសិនបើយើងខ្ញុំដឹងអំពីលទ្ធភាពដែលអាចមានទំនាស់ផលប្រយោជន៍បែបនេះ យើងខ្ញុំនឹងរាយការណ៍ជាបន្ទាន់ ទៅកាន់សមត្ថកិច្ចមួយ ឬច្រើន ដូចតទៅៈ គណៈកម្មការលទ្ធកម្មឃុំ អភិបាលខេត្ត អភិបាលស្រុក ក្រុមការងារ គណនេយ្យភាពខេត្ត។

៣.ខ្ញុំ និយោជិតរបស់ខ្ញុំ អ្នកផ្តល់សេវាបច្ចេកទេសរបស់ខ្ញុំ សមាគម/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ភាគហ៊ុនិករបស់ខ្ញុំ សម្ព័ន្ធញាតិរបស់ខ្ញុំ និងសមាគតនិងសម្ព័ន្ធញាតិរបស់ពួកគេមិនបានប្រព្រឹត្តអំពើពុករលួយ លួចបន្លំ បង្កាប់បញ្ជា ឬ ស៊ីគ្រលំគ្នាក្នុងដំណើរការកិច្ចសន្យានេះឡើយ។

៤. យើងខ្ញុំដឹងនូវកាតព្វកិច្ចរបស់យើងខ្ញុំដែលត្រូវអនុញ្ញាតឱ្យស្ថាប័នរដ្ឋាភិបាល និង/ឬស្ថាប័នផ្តល់មូលនិធិ ធ្វើអធិការកិច្ចលើ រាល់ឯកសារដែលពាក់ព័ន្ធនឹងការរៀបចំគម្រោងស្នើនិងកិច្ចសន្យាណាមួយរបស់យើង ដែលបណ្តាលមកពីទំនាក់ទំនងនេះ ទោះជាបានទទួល ឬមិនបានទទួលកិច្ចសន្យាក្តី។

៥. ពាក់ព័ន្ធនឹងការងារលទ្ធកម្មនេះ និងពាក់ព័ន្ធជាមួយកិច្ចសន្យាណាមួយដែលបានទទួល ខ្ញុំ និយោជិករបស់ខ្ញុំ អ្នកផ្តល់សេវាបច្ចេកទេសរបស់ខ្ញុំ សមាគម/ដៃគូរបស់ខ្ញុំ ភ្នាក់ងាររបស់ខ្ញុំ ភាគហ៊ុនិករបស់ខ្ញុំ សម្ព័ន្ធញាតិរបស់ខ្ញុំ និងសមាគមនិងសម្ព័ន្ធញាតិរបស់ពួកគេ មិនបានផ្តល់ប្រាក់ ឬការទូទាត់ជាវត្ថុណាមួយទៅឱ្យបុគ្គលិក អ្នកផ្តល់សេវាបច្ចេកទេស សមាគម ឬសម្ព័ន្ធញាតិណាមួយនៅក្នុងដំណាក់កាលលទ្ធកម្ម នៅក្នុងការប្រគល់ និងការអនុវត្តកិច្ចសន្យា ព្រមទាំងការទូទាត់ណាមួយឡើយ។

ក្នុងករណីដែលខ្ញុំមិនគោរពតាមសេចក្តីប្រកាសនេះទេនោះខ្ញុំបញ្ជាក់ហើយយល់ថា ក្នុងឋានៈជាអ្នកផ្តល់សេវាបច្ចេកទេស ខ្ញុំអាចនឹងប្រឈមមុខនឹងការមិនអនុញ្ញាតឱ្យដាក់ពាក្យចំពោះគម្រោងមូលនិធិឃុំ/សង្កាត់នៅទូទាំងប្រទេសកម្ពុជា។

កាលបរិច្ឆេទៈ...........................................................................................................

ហត្ថលេខាៈ...........................................................................................................

ឈ្មោះអ្នកផ្តល់សេវាបច្ចេកទេសៈ........................................................................................